# ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ខេត្ត ចុះមូលដ្ឋានខេត្តកំពត ត្រូវបន្តចុះជួយដោះស្រាយបញ្ហា និងសំណូមពរ ជូនប្រជាពលរដ្ឋ ឲ្យដូចត្នៀងរលីម




**(កំពត)៖** នាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត បានអញ្ជើញជាអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររយៈពេល០២ ខែ និងទិសដៅអនុវត្តបន្ត របស់ក្រុមការងារថ្នាក់ជាតិខេត្តចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅសាលប្រជុំសាលាខេត្តកំពត។

តាមរបាយការណ៍របស់**ឯកឧត្តម ចាន់ ចេស្តា** អភិបាល នៃគណៈអភិបាលខេត្តកំពត បានបញ្ជាក់ថា៖ ក្រុមការងារចុះមូលដ្ឋានខេត្ត និងក្រុង/ស្រុក បានចុះសំណេះសំណាល និងស្វែងរកតម្រូវការ បញ្ហាប្រឈម និងសំណូមពររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ តាមបណ្ដាក្រុង ស្រុក ក្នុងរយៈពេល០២ ខែកន្លងទៅនេះ សរុបចំនួន២២លើក ស្មើនឹង២១ ឃុំ សង្កាត់ មានការចូលរួមពីក្រុមការងារចំនួន ៥១២នាក់ និងប្រជាពលរដ្ឋចំនួន ៣.២៥០នាក់ ស្រី ១.៤៨២នាក់ ដោយប្រមូលបានបញ្ហា សំណូមពរចំនួន ១១៦ ករណី។ ក្នុងនោះបាន ដោះស្រាយចំនួន ៧០ ករណី កំពុងដោះស្រាយ ៣៥ ករណី និងមិនទាន់ដោះស្រាយចំនួន ១១ ករណី ។



**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខ និងថ្លែងការកោតសរសើរពីសម្ដេចតេជោនាយករដ្ឋមន្ត្រី ជូនចំពោះ អស់លោក លោកស្រី ស្ថិតក្នុងក្រុមការងារថ្នាក់ជាតិគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលបានខិតខំប្រឹងប្រែងចុះធ្វើវេទិកាសាធារណៈ ដើម្បីដោះស្រាយសំណូមពរនានា ដែលធ្វើឲ្យបញ្ហាត្រូវបានដោះស្រាយជាបន្តបន្ទាប់ ហើយទទួលបានទំនុកចិត្តពីប្រជាពលរដ្ឋ លើការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល។

ដើម្បីជាការលើកទឹកចិត្តដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារគ្រប់លំដាប់ថ្នាក់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានស្នើរួចហើយដល់រាជរដ្ឋាភិបាល ក្នុងការផ្ដល់ជូននូវមេដាយការងារ និងគ្រឿងឥស្សរិយយស ជូនដល់មន្ត្រីផ្ញើមទាំងអស់នៅពេលខាងមុខឆាប់ៗនេះ។ ជាមួយគ្នានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានកោតសរសើរដល់ក្រុមការងារ ជាពិសេស**ឯកឧត្តមទេសរដ្ឋមន្ត្រី ប៉ែន ស៊ីម៉ន** អនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត ដែលបានយកចិត្តទុកដាក់ខ្ពស់ចំពោះទាំងគ្រូ និងសិស្ស រហូតធ្វើឲ្យលទ្ធផលសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៧នេះ នៅទូទាំងខេត្តកំពត សិស្សប្រឡងជាប់ចំណាត់ថ្នាក់និទ្ទេសA បានកើនឡើងលើសឆ្នាំមុនចំនួន១០នាក់ គឺ ឆ្នាំនេះទទួលបាន ២១នាក់ ដែលកាលពីឆ្នាំ២០១៦បានត្រឹមតែ១១នាក់ ប៉ុណ្ណោះ។

ចំណុចនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** គាំទ្រ និងណែនាំឲ្យបន្តការយកចិត្តទុកដាក់ទាំងអ្នកជាប់ និងអ្នកធ្លាក់ ដើម្បីជម្រុញ និងលើកទឹកចិត្តដល់ពួកគេឲ្យមានការខិតខំសិក្សា

ដើម្បីឈានដល់គោលដៅជាអតិបរមា។

ក្នុងន័យឆ្លើយតប ក៏ដូចជាការដាស់តឿន **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានណែនាំការងារជាក់ស្ដែងមួយចំនួនដូចជាហាមប្រជាពលរដ្ឋក៏ដូចជាមន្ត្រីចូលទៅចាប់ដីរបស់រដ្ឋធ្វើកម្មសិទ្ធិ, ខិតខំថែរក្សាការពារដីស្រែអំបិលដើម្បីថែរក្សារបរប្រពៃណីរបស់ខ្មែរយូរលង់មកហើយ, ខិតខំរកនីតិវិធីសមស្របដើម្បីដោះស្រាយដីចំណីព្រែក ដែលមានការពាក់ព័ន្ធជាមួយប្រជាពលរដ្ឋមួយចំនួន, ពិនិត្យលទ្ធភាពស្នើសុំរាជរដ្ឋាភិបាលដើម្បីបើកច្រកទ្វារភាគីនៅស្រុកបន្ទាយមាស ងាយស្រួលប្រជាជនទាំងសងខាងកម្ពុជា-វៀតណាម ដោះដូរទំនិញ រឺផលិតផល ជាមួយគ្នា, ពន្លឿនការងារកំណត់ព្រំប្រទល់ខេត្តរវាងស្រុកដំណាក់ចង្អើរខេត្តកែប និង ស្រុកកំពង់ត្រាចខេត្តកំពត។




ជាមួយគ្នានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** ក៏បានស្នើឲ្យក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនសម្រួល និងសហការដើម្បីឲ្យការអនុវត្តគម្រោងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មលើវិស័យទឹកស្អាត ជាមួយដៃគូនានាប្រកបដោយជោគជ័យ។


ខេត្តកំពត

ជាចុងក្រោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** ស្នើឲ្យក្រុមការងារទាំងអស់បន្ត និងកាន់តែសកម្មឡើង ក្នុងការចុះធ្វើវេទិកាសាធារណៈ និងចុះសួរសុខទុក្ខដល់ខ្នងផ្ទះប្រជាពលរដ្ឋជាមួយនិងការបម្រើសេវាសាធារណៈឲ្យបានកាន់តែប្រសើរ។ ព្រមទាំងផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវទង្វើក្បត់ជាតិរបស់មេបក្សប្រឆាំង ដែលត្រូវរាជរដ្ឋាភិបាលឃុំខ្លួនតាមអំណាចសាលក្រមរបស់តុលាការពីបទឃុបឃិតជាមួយបរទេសក្នុងការផ្តួលរំលំរាជរដ្ឋាភិបាលកម្ពុជាស្របច្បាប់។